**ម៉ូរីសុនកាក់ អិមខេអេ**
**Morisonkak MKA**
Audit-Accounting-Tax & Business Advisory

# សេចក្តីជូនដំណឹង
# ស្តីពី
# ការផ្តល់សំណងចំពោះអ្នកដាក់ប្រាក់បញ្ញើរបស់ធនាគារ ព្រីនស៍ ម.ក

**ក្រុមហ៊ុន ម៉ូរីសុនកាក់ អិមខេអេ អឌីត-អ៊ីខោនធីង ឯ.ក** (Morisonkak MKA Audit-Accounting Co., Ltd) ដែលត្រូវបានតែងតាំងដោយធនាគារជាតិនៃកម្ពុជាធ្វើជាអ្នកជម្រះបញ្ជីធនាគារ ព្រីនស៍ ម.ក សូមជម្រាបជូនដំណឹងដល់សាធារណជនមេត្តាជ្រាបថា ក្រោមការអនុវត្តនីតិវិធីបំប្លែងទ្រព្យសកម្មរបស់ធនាគារ ព្រីនស៍ ម.ក ទៅជាសាច់ប្រាក់ អ្នកជម្រះបញ្ជីសូមអញ្ជើញអ្នកដាក់ប្រាក់បញ្ញើទាំងអស់ មកទទួលសំណង ចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៦ នៅការិយាល័យធនាគារ ព្រីនស៍ ម.ក ដែលមានទីតាំងនៅអគារលេខ ៩៤៥ ជាន់ទី១, ១៥ & ១៨ មហាវិថីព្រះមុនីវង្ស កែងផ្លូវ២៣២ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ ដោយភ្ជាប់មកជាមួយឯកសារពាក់ព័ន្ធ។

ការផ្តល់សំណងនឹងត្រូវធ្វើឡើងតាមរយៈ **១/- ការផ្ទេរតាមគណនីធនាគារ** សម្រាប់អ្នកដាក់ប្រាក់បញ្ញើដែលបានផ្តល់ព័ត៌មានគណនីធនាគារ និង **២/- ការផ្តល់សំណងដោយផ្ទាល់** នៅការិយាល័យធនាគារ ព្រីនស៍ ម.ក តាមអាសយដ្ឋានខាងលើ សម្រាប់អ្នកដាក់ប្រាក់បញ្ញើដែលពុំបានផ្តល់ព័ត៌មានគណនីធនាគារក្នុងពាក្យស្នើសុំទាមទារសំណង។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងក្រុមការងារជម្រះបញ្ជីតាមរយៈទូរសព្ទលេខ ០២៣ ៩៩១ ១៦៨ និង ១៨០០ ២០៨ ៨៨៨។

អាស្រ័យហេតុនេះ សូមអ្នកដាក់ប្រាក់បញ្ញើរបស់ធនាគារ ព្រីនស៍ ម.ក និងសាធារណជនទូទៅ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១៥រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៦
**ក្រុមហ៊ុន ម៉ូរីសុនកាក់ អិមខេអេ អឌីត-អ៊ីខោនធីង ឯ.ក**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ម៉ូរីសុនកាក់ អិមខេអេ អឌីត-អ៊ីខោនធីង ឯ.ក MORISONKAK MKA AUDIT-ACCOUNTING CO., LTD. KINGDOM OF CAMBODIA

**MORISONKAK MKA AUDIT - ACCOUNTING CO., LTD.**
NO 10, STREET 500, SANGKAT PHSAR DOEUM THKOV, KHAN CHAMKARMON, PHNOM PENH
TEL: +855 23 218 994 (3 LINES) - FAX: +855 23 218 993 - Email: mka.audit@morisonkak.com
Email: mka.management@morisonkak.com - Website: www.morisonkak.com

Independent member Morison Global